**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...២១៥...ស.ខ.ល

# សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

## ស្តីពី

## ករណីមានការរៀបចំពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមភូមិ-ឃុំ និងនៅទីវត្តអារ៉ាម ក្នុងបរិបទនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្វីត្បិតតែឆ្នាំ២០២០នេះ ព្រះរាជាណាចក្រកម្ពុជាយើងមិនមានប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅរាជធានីភ្នំពេញក៏ដោយ ក៏ប៉ុន្តែតាមការសង្កេតឃើញថា អាចមានក្រុមប្រជាពលរដ្ឋខ្លះ មានរៀបចំការប្រណាំងទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ ដោយក្រុមតូចៗរបស់គាត់នៅតាមភូមិ-ឃុំ និងនៅតាមទីវត្តអារ៉ាម ឬនៅតាមផ្ទះសម្បែង ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ពីអាជ្ញាធរមូលដ្ឋាន និងក្រុមអ្នករៀបចំពិធីនេះ ក្នុងការធានាមិនឲ្យមានការចម្លងវីរុសកូវីដ-១៩ ចូលក្នុងសហគមន៍យើង។

ក្រសួងសុខាភិបាលសូមរំលឹកជូនថា ស្ថានភាពនៃការចម្លងនៃវីរុសកូវីដ-១៩ នៅបណ្តាប្រទេសលើសកលលោក និងនៅក្នុងតំបន់ មិនទាន់មានការធូរស្បើយនៅឡើយទេ ឯកំណើននៃការចម្លងវីរុសកូវីដ-១៩ និងការស្លាប់ដោយសារជំងឺនេះ ក៏នៅតែបន្តមានខ្ពស់នៅឡើយដែរ បើទោះបីជាប្រទេសកម្ពុជា មិនទាន់មានការចម្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ក៏ដោយ ក៏ហានិភ័យនៃការចម្លងវីរុសដ៏កាចសាហាវនេះ នៅតែមាន ហើយការចម្លងអាចកើតមានឡើងគ្រប់ពេលវេលា គ្រប់កាលទេសៈ និងគ្រប់ទីកន្លែង។

ដូច្នេះ ក្រសួងសុខាភិបាលសូមធ្វើការក្រើនរំលឹក និងអំពាវនាវសារជាថ្មីជូនដល់សាធារណជន ក្រសួងពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ បន្តចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍យើង ដោយទាំងអស់គ្នា ត្រូវតែបន្តអនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងការណែនាំរបស់ក្រសួងសុខាភិបាល ដែលបានធ្វើជារឿយៗ ហើយនៅក្នុងឱកាសនេះ ប្រសិនបើបងប្អូនប្រជាពលរដ្ឋនៅតាមភូមិ-ឃុំ មានរៀបចំពិធីអបអរសាទរព្រះរាជពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ ខាងមុខនេះ ក្រសួងសូមណែនាំដល់បងប្អូនប្រជាពលរដ្ឋ មិនត្រូវមានការជួបជុំគ្នាក្នុងទ្រង់ទ្រាយធំឡើយ ហើយត្រូវចាត់ចែងរៀបចំការប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ទៅតាមភូមិ-ឃុំ វត្តអារ៉ាម (មិនត្រូវធ្វើនៅថ្នាក់ខេត្តឡើយ ដែលបង្កឲ្យមានការប្រមូលផ្តុំគ្នាច្រើនពេក) ទៅតាមស្ថានភាពជាក់ស្តែង និងទីតាំងដែលអាចធ្វើបានតែប៉ុណ្ណោះ ដោយចាំបាច់ត្រូវធ្វើក្នុងទ្រង់ទ្រាយតូចៗ ដែលចំណុះទូកនីមួយៗ មិនឲ្យលើសពី ១០នាក់ និងមិនឲ្យលើសពី ៦ទូក ក្នុងមួយពិធី ហើយមិនឲ្យលើសពី ៦០នាក់ សម្រាប់អ្នកចូលទស្សនា ព្រមទាំងត្រូវឲ្យមានគម្លាតសុវត្ថិភាពបុគ្គលយ៉ាងតិចមួយម៉ែត្រកន្លះ សម្រាប់អ្នករង់ចាំអុំទូក និងត្រូវអនុវត្តតាមគោលការណ៍ណែនាំសំខាន់ៗដូចខាងក្រោម រួមមាន៖

**ក.អាជ្ញាធររាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ រដ្ឋបាលភូមិ-ឃុំ/សង្កាត់ និងសុខាភិបាលមូលដ្ឋាន ទាំងអស់ ត្រូវសហការគ្នា ដោយមានចាត់តាំងកម្លាំង ចាត់ចែង គ្រប់គ្រង ឃ្លាំមើល និងធ្វើការណែនាំការអនុវត្តឲ្យបានខ្ជាប់ខ្ជួនប្រកបដោយប្រសិទ្ធភាព នូវវិធានការការពារដូចខាងក្រោមនេះ៖**

១. បន្តធ្វើឲ្យសកម្មនូវដំណើរការគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជធានី-ខេត្ត ជាបន្តទៅទៀត ហើយត្រូវចាត់តាំងកម្លាំងឲ្យបានសមស្រប សម្រាប់ជួយសម្របសម្រួល និងតាមដានការអនុវត្តវិធានការសុខាភិបាលនៅតាមទីតាំងដែលមានរៀបចំការប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ដើម្បីបញ្ចៀសនូវការចម្លងវីរុសកូវីដ-១៩ នៅតាមទីតាំងដែលមានសកម្មភាពទាំងនេះ នៅតាមភូមិ-ឃុំ។

២. អ្នកចាត់ចែង អ្នកអុំទូក អ្នកចូលទស្សនា និងគ្រប់ៗគ្នា ត្រូវពាក់ម៉ាស់ជាចាំបាច់ រហូតដល់ពិធីចប់ជាស្ថាពរ។

៣. ត្រូវរៀបចំឲ្យមានកន្លែងលាងដៃ នៅតាមច្រកចេញ-ចូល មុននឹងចូលទៅកាន់កន្លែងពិធីប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក។

៤. ត្រូវចាត់ឲ្យវាស់កំដៅខ្លួនបុគ្គលនីមួយៗ និងបាញ់ទឹកអាល់កុលលាងដៃ ជូនដល់គ្រប់អ្នកដែលចូលទៅកាន់ទីតាំងមានពិធី ជាពិសេស កុំឲ្យមានការធ្វេសប្រហែសឲ្យសោះ នៅតាមមុខច្រកចេញ-ចូល នីមួយៗ។

៥. ចាត់ចែងឲ្យមានការតម្រង់ជួរ ដោយឈរ ឬអង្គុយ ឲ្យមានគម្លាតពីគ្នាយ៉ាងតិចមួយម៉ែត្រកន្លះ នូវរាល់ពេលដែលមានការចូលទៅកាន់ទីកន្លែងប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ជាដើម។

៦. ចាត់ចែងឲ្យមានការអង្គុយ ឬឈរ ទស្សនាការប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ដោយមានគម្លាតសុវត្ថិភាពបុគ្គលយ៉ាងតិចមួយម៉ែត្រកន្លះ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់។

៧. ពិនិត្យតាមដានអ្នកចូលរួមពិធីទាំងអស់ បើមានករណីគ្រុនក្តៅ ឬគ្រុនផ្តាសាយ មិនត្រូវអនុញ្ញាតឲ្យចូលទៅកាន់កន្លែងមានពិធីណាមួយ ឬឲ្យគាត់ឈប់ទស្សនា និងត្រូវឲ្យគាត់វិលត្រឡប់ទៅផ្ទះគាត់វិញ បន្ទាប់មក ត្រូវស្វែងរកការពិគ្រោះជំងឺនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋ ដែលនៅជិតលោកអ្នក និងរាយការណ៍មកទូរស័ព្ទទាន់ហេតុការណ៍លេខ ១១៥ នូវរាល់ករណីសង្ស័យឆ្លងជំងឺកូវីដ-១៩ ឬមានបញ្ហាសុខភាពណាមួយ។

៨. ត្រូវចាត់ចែង ដោយកំណត់ចំណុះទូក ដែលមានអ្នកអុំ មិនត្រូវលើសពី ១០នាក់ ក្នុងទូកនីមួយៗ និងត្រូវតែមានគម្លាតសុវត្ថិភាពបុគ្គលពីគ្នាយ៉ាងតិចមួយម៉ែត្រកន្លះ ព្រមទាំងត្រូវពាក់ម៉ាស់ជាប់ជាប្រចាំ និងមានការរក្សាអនាម័យដៃឲ្យបានស្អាតជានិច្ច។

១០. ណែនាំប្រជាជនក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ឲ្យអនុវត្តវិធានការសុខាភិបាលខ្ជាប់ខ្ជួនស្របតាមរបត់នៃ "*ការរស់នៅបែបថ្មី តាមបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*" ដោយប្រកាន់យកជាចាំបាច់នូវ៖

- ការអនុវត្តអនាម័យដៃស្អាត (លាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូនឹងទឹកស្អាត ទឹកអាល់កុល ឬជែលសម្រាប់លាងដៃ ចៀសវាងការយកដៃកខ្វក់ មិនបានលាងសម្អាត មកប៉ះផ្ទៃមុខ មាត់ ឬច្រមុះ)
- ពាក់ម៉ាស់ក្នុងករណីចាំបាច់ ប្រើក្រមា កែងដៃ ឬក្រដាសជូតមាត់ ខ្ទប់មាត់ពេលមានក្អកកណ្តាស់ និង
- បន្តអនុវត្តគម្លាតសុវត្ថិភាពសង្គម និងសុវត្ថិភាពបុគ្គលយ៉ាងតិចមួយម៉ែតកន្លះ។

**ខ.ចំពោះអ្នកចូលទៅកាន់កន្លែងមានពិធី អ្នកទៅចូលរួមទស្សនា អ្នកប្រណាំងទូក និងអ្នកចូលរួមចាត់ចែងគ្រប់គ្រងបរិវេណប្រណាំងនៅតាមភូមិ-ឃុំ ត្រូវអនុវត្តដូចតទៅ៖**

១. គ្រប់រូបដែលចូលទៅកាន់ទីកន្លែងមានពិធី អ្នកទស្សនា អ្នកប្រណាំងទូក និងអ្នកចូលរួមចាត់ចែងគ្រប់គ្រងបរិវេណប្រណាំងទូក ព្រមទាំងគណៈកម្មការទូកទាំងអស់ បើមានរោគសញ្ញាដូចជា៖ គ្រុនក្តៅ ក្អក ឈឺក្បាល ហៀរសំបោរ សូមកុំចូលរួមនៅក្នុងពិធីនេះ ដើម្បីការពារការចម្លងជំងឺទៅអ្នកដទៃ និងសូមស្វែងរកការពិគ្រោះយោបល់នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋ ដែលនៅជិតលោកអ្នក។

២. ត្រូវយកទៅតាមខ្លួនជាប់ជានិច្ចនូវទឹកអាល់កុល ឬជែល សម្រាប់លាងដៃ ហើយ៖

- ត្រូវលាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូនឹងទឹកស្អាត ឬទឹកអាល់កុល ជែលលាងដៃ ឲ្យបានញឹកញាប់ និងជាប់ជាប្រចាំ។ ចៀសវាងការយកដៃកខ្វក់មិនបានលាងសម្អាត មកប៉ះផ្ទៃមុខ មាត់ ឬច្រមុះ របស់លោកអ្នក។

- ត្រូវពាក់ម៉ាស់ជាប់ជានិច្ចរហូតដល់ចប់ពិធីនីមួយៗ។
- ត្រូវខ្ទប់មាត់ និងច្រមុះ ពេលក្អក កណ្តាស់ ដោយប្រើម៉ាស់ ក្រម៉ា កន្សែង កែងដៃ ឬក្រដាសអនាម័យ រួចខ្ទប់បោះចោលក្នុងធុងសម្រាប់បិទជិត និងត្រូវធ្វើដំណើរត្រឡប់មកផ្ទះវិញភ្លាម ប្រសិនបើមានគ្រុនក្តៅ ក្អក ឈឺក្បាល ហៀរសំបោរ រួចទៅស្វែងរកការពិគ្រោះយោបល់នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋ ដែលនៅជិតលោកអ្នក។
- ត្រូវជៀសវាងការខាកស្តោះពាសវាលពាសកាល ដែលជាហេតុឲ្យមានការចម្លងរោគបន្តគ្នា។
- ត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គល ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត យ៉ាងតិចមួយម៉ែត្រកន្លះ នៅពេលឈរ អង្គុយ ឈររង់ចាំ ឈរជជែកគ្នា ឬនៅទីកន្លែងផ្សេងៗ ដូចជាកន្លែងរៀបចំពិធី កន្លែងសាធារណៈ ភោជនីយដ្ឋាន អាហារដ្ឋាន ទីកន្លែងកំសាន្តលំហែកាយ ឬទីកន្លែងទេសចរនានា ជាដើម។
- អ្នកដែលមានហានិភ័យខ្ពស់នៃការចម្លងជំងឺ ដូចជា ជនចាស់ជរា ជនដែលមានជំងឺប្រចាំកាយ ស្ត្រីមានផ្ទៃពោះ ជាដើម មិនត្រូវចូលរួមពិធី បើមិនមានការចាំបាច់បំផុតនោះទេ ត្រូវតែមានការអនុវត្តកិច្ចការពារខ្លួនឲ្យបានល្អ និងរក្សាគម្លាតសុវត្ថិភាពបុគ្គល ព្រមទាំងមានអ្នកជួយមើលការខុសត្រូវឲ្យបានត្រឹមត្រូវ ព្រមទាំងអនុវត្តវិធានការដូចជម្រាបជូនខាងលើនេះ។

ជាមួយនឹងវិធានការការពារការចម្លងវីរុសកូវីដ-១៩ បងប្អូនត្រូវរក្សាអនាម័យចំណីអាហារ និងកុំពិសាស្រាដែលមិនមានប្រភពផលិតច្បាស់លាស់ និងអនុញ្ញាតដោយស្ថាប័នមានសមត្ថកិច្ច។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់ចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ របស់បងប្អូនប្រជាពលរដ្ឋទាំងអស់ និងអាជ្ញាធររាជធានី-ខេត្ត ស្រុក ក្រុង ខណ្ឌ រដ្ឋបាលឃុំ/សង្កាត់ទាំងអស់ ហើយក្រសួងក៏សូមអំពាវនាវដល់សាធារណជនទាំងអស់ សូមចូលរួមអនុវត្តតាមការណែនាំខាងលើនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកកាត់ផ្តាច់ការចម្លងវីរុសកូវីដ-១៩ ពីបុគ្គលម្នាក់ទៅម្នាក់ និងកុំឲ្យមានការចម្លងចូលក្នុងសហគមន៍។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានបញ្ហាសុខភាព ឬមានជំងឺ ឬសង្ស័យថាមាការឆ្លងជំងឺ សូមប្រញាប់ទៅស្វែងរកការពិនិត្យពិគ្រោះនៅមន្ទីរពេទ្យរដ្ឋ ឬទំនាក់ទំនងតាមលេខផ្តល់ជូនខាងក្រោមនេះ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តន៍នៃបញ្ហាសុខភាពតាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួងសុខាភិបាល www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារអប់រំសុខភាព ដែលអាចទាញយកមកមើល និងប្រើប្រាស់បាន។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០
រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន
គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

ម៉ម_ប៊ុនហេង

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-រដ្ឋបាលរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ